E359/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 08 / 2015
ម៉ោង (Time/Heure): 16:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
*Chambre de première instance*

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសង
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

អៀង ធីរិទ្ធ

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GIRAUD

**មេធាវីជនជាប់ចោទ**

Diana ELLIS
ផាត់ ពៅស៊ាង

01134387

E359/1

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំបុត្រមរណភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ[1]។

## ១. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ អៀង ធីរិទ្ធ ត្រូវបានចាប់ខ្លួនតាមដីការបស់សហចៅក្រមស៊ើបអង្កេត និង ត្រូវបានជូនដំណឹងពីបទចោទនានាប្រឆាំងនឹងរូបគាត់[2]។ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាចោទប្រកាន់បញ្ជូន អៀង ធីរិទ្ធ ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និង ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[3]។ កិច្ចដំណើរការនីតិវិធីជំនុំជម្រះបានចាប់ផ្ដើមដំណើរការ ដោយមានសវនាការបឋមនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១[4]។

៣. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការទេ ដោយសារគាត់មានជំងឺវង្វេងវង្វាន់ស្មារតី ហើយអង្គជំនុំជម្រះបានសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់ និង ដោះលែងរូបគាត់ដោយឥតលក្ខខណ្ឌ[5]។ បន្ទាប់ពីមានបណ្ដឹងសាទុក្ខដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់អង្គជំនុំជម្រះសាលាដំបូងឱ្យមានការព្យាបាលបន្ថែមដល់ អៀង ធីរិទ្ធ ដែលអាចជួយឱ្យសុខភាពផ្នែកបញ្ញាស្មារតីរបស់គាត់បានប្រសើរឡើងដល់កម្រិតមួយដែលឱ្យគាត់អាចមានសម្បទាចូលរួមសវនាការបាន[6]។ បន្ទាប់មក អៀង ធីរិទ្ធ បានទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ និង ការព្យាបាលដោយចលនាឱ្យបញ្ញាស្មារតីរបស់គាត់មានភាពប្រសើរ ពីថ្ងៃទៅ ២៧ ខែ មីនា ឆ្នាំ

---

1 សំបុត្រមរណភាពរបស់ អៀង ធីរិទ្ធ ឯកសារ E359.3 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥។

2 សេចក្ដីសម្រេចឃាត់ខ្លួន អៀង ធីរិទ្ធ ឯកសារ C15 ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៧, កំណត់ហេតុនាំខ្លួន អៀង ធីរិទ្ធ ឯកសារ C13/I ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ដីកាបង្គាប់នាំខ្លួន អៀង ធីរិទ្ធ ឯកសារ C13 ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

3 ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ ១៦១៣។

4 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី - សាធារណៈ - សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E1/4 ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១។

5 សេចក្ដីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E138 ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។

6 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារ E138/1/7 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ ផ្នែកសម្រេចសេចក្ដី។

២០១២[7]។ នៅខែ សីហា ឆ្នាំ ២០១២ បន្ទាប់ពី អៀង ធីរិទ្ធ បានទទួលការព្យាបាល អង្គជំនុំជម្រះសាលាដំបូងបានកោះហៅអ្នកជំនាញដែលត្រូវបានចាត់តាំងដោយតុលាការ មកវាយតម្លៃម្តងទៀតពីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ[8]។ នៅក្នុងរបាយការណ៍របស់ខ្លួន អ្នកជំនាញបានយល់ស្របគ្នាថា ជំងឺវង្វេងវង្វាន់ស្មារតីរបស់ អៀង ធីរិទ្ធ កាន់តែមានសភាពធ្ងន់ធ្ងរឡើងៗចាប់តាំងពីឆ្នាំ ២០១១ មក ហើយថា សមត្ថភាពសតិបញ្ញារបស់គាត់បានធ្លាក់ចុះបន្តិចបន្តួចថែមទៀតក្នុងរយៈពេលប៉ុន្មានខែចុងក្រោយ ទោះបីជាមានការព្យាបាលថ្មីៗក៏ដោយ[9]។ នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់សាជាថ្មីថា អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការសវនាការទេ ហើយបានដោះលែងគាត់ម្តងទៀត[10]។

៤. បន្ទាប់ពីមានបណ្តឹងសាទុក្ខបន្ថែមមួយដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យមានរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលត្រូវអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូង[11]។ មួយផ្នែកនៃរបបត្រួតពិនិត្យនេះបានតម្រូវឱ្យ អៀង ធីរិទ្ធ ទទួលការត្រួតពិនិត្យផ្នែកវេជ្ជ-

---

7 ចម្លើយតបរបស់អ្នកជំនាញចំពោះសំណួរពាក់ព័ន្ធនឹងរយៈពេលព្យាបាលដោយឱសថ rivastigmine និង ក្របខណ្ឌពេលវេលាសម្រាប់ការវាយតម្លៃឡើងវិញអំពីសម្បទាដើម្បីចូលរួមសវនាការរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារ E138/1/7/9 ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៣-៤។

8 ការកំណត់កាលបរិច្ឆេទនៃការវាយតម្លៃលើបញ្ហាកាយសម្បទា និង សតិបញ្ញាស្មារតីឡើងវិញ និង សវនាការស្តីពីបញ្ហាកាយសម្បទា និង សតិបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារ E138/1/7/13 ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២។

9 របាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹងលោកស្រី អៀង ធីរិទ្ធ ឯកសារ E138/1/7/13/2 ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៦១។

10 សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E138/1/10 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១២។

11 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ឯកសារ E138/1/10/1/5/7 ("សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល") ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ ផ្នែកសម្រេចសេចក្តី។

សាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការផ្ទៀងផ្ទាត់ស្ថានភាពនៃសតិបញ្ញារបស់គាត់[12]។

៥. នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានចាត់តាំងអ្នកជំនាញមួយរូបឱ្យធ្វើការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រលើស្ថានភាពសតិបញ្ញារបស់ជនជាប់ចោទរៀងរាល់ប្រាំមួយខែម្តង[13]។ អ្នកជំនាញបានរាយការណ៍ថា ស្ថានភាពសតិបញ្ញារបស់ អៀង ធីរិទ្ធ បន្តធ្លាក់ចុះចាប់តាំងពីការវាយតម្លៃលើកចុងក្រោយ[14]។ ជារឿយៗ អៀង ធីរិទ្ធ មិនចាំ ឬ មិនស្គាល់សមាជិកគ្រួសារជិតស្និទ្ធរបស់គាត់ ហើយភ្លេចថាប្តីគាត់បានស្លាប់ទៅហើយផង[15]។ ជារឿយៗ គាត់ទំនងជាច្រឡំសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និង មិនចាំទីតាំងបន្ទប់នានានៅក្នុងផ្ទះរបស់គាត់ផងទេ[16]។ អ្នកជំនាញបានសន្និដ្ឋានថា អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ស្មារតីពីកម្រិតមធ្យមទៅកម្រិតធ្ងន់ធ្ងរ[17]។ នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ អ្នកជំនាញបានកត់សម្គាល់ថា ការថតស្កែនលលាដ៏ក្បាល (CT scan) ដែលបានធ្វើនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ជាមួយនឹងការថតស្កែនលលាដ៏ក្បាលបីលើកកាលពីឆ្នាំ ២០០៧ ២០០៩ និង ២០១១ បានបង្ហាញអំពីភាពរួញនៃខួរក្បាលរបស់គាត់[18]។ ការថតស្កែនលលាដ៏ក្បាលនៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ក៏បានបង្ហាញផងដែរថា អៀង ធីរិទ្ធ មានជំងឺ

12 សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ផ្នែកសម្រេចសេចក្តី, សេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និង មេធាវីការពារក្តី អៀង ធីរិទ្ធ សុំការណែនាំ និង ការបញ្ជាក់បំភ្លឺ ឯកសារ E138/1/10/1/5/8/2 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១១។

13 ការតែងតាំងវេជ្ជបណ្ឌិតដើម្បីអនុវត្តការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រលើ អៀង ធីរិទ្ធ រៀងរាល់ប្រាំមួយខែម្តង ឯកសារ E138/1/10/1/5/9 ចុះថ្ងៃទី ០១ ខែ តុលាការ ឆ្នាំ ២០១៣។

14 ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រមកលើ អៀង ធីរិទ្ធ រៀងរាល់ប្រាំមួយខែម្តង ដើម្បីជាការឆ្លើយតបទៅនឹងសំណើរបស់អង្គ-ជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៣ ឯកសារ E138/1/10/1/5/9/2 ("របាយការណ៍អំពីការត្រួតពិនិត្យរៀងរាល់ប្រាំមួយខែលើកទីមួយ") ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦។

15 របាយការណ៍អំពីការត្រួតពិនិត្យរៀងរាល់ប្រាំមួយខែលើកទីមួយ កថាខណ្ឌ ១៧-១៩, ២៤។

16 របាយការណ៍អំពីការត្រួតពិនិត្យរៀងរាល់ប្រាំមួយខែលើកទីមួយ កថាខណ្ឌ ១៧, ១៩។

17 របាយការណ៍អំពីការត្រួតពិនិត្យរៀងរាល់ប្រាំមួយខែលើកទីមួយ កថាខណ្ឌ ២៥។

18 ការត្រួតពិនិត្យលើលទ្ធផលថតស្កែនរបស់លោកស្រី អៀង ធីរិទ្ធ ឯកសារ E138/1/10/1/5/9/6 ("របាយការណ៍អំពីលទ្ធផលថតស្កែនថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២") ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

គៀតសសៃឈាមតូចៗ (mini strokes) ពីរកន្លែង ចាប់តាំងពីការថតស្កេនលលាដ៏ក្បាលរបស់គាត់លើកចុងក្រោយនៅឆ្នាំ ២០១១ មក[19]។

៦. នៅថ្ងៃ ០៦ ខែ មីនា ឆ្នាំ ២០១៤ កូនស្រីរបស់ អៀង ធីរិទ្ធ ដែលជាអាណាព្យាបាលរបស់គាត់ បានជូនដំណឹងមកអង្គជំនុំជម្រះថា អៀង ធីរិទ្ធ បានទទួលរងរបួសដោយសារគាត់ដួល និង មិនអាចក្រោកពីគ្រែរួចចាប់ពីពេលនោះ និង បានស្នើសុំការអនុញ្ញាតយក អៀង ធីរិទ្ធ ទៅព្យាបាលនៅប្រទេសថៃ[20]។ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតទៅតាមសំណើសុំ[21]។ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ អាណាព្យាបាលរូបនេះបានរាយការណ៍ថា អៀង ធីរិទ្ធ បានទទួលការព្យាបាលនៅមន្ទីរពេទ្យ Bangkok Hospital ដែលគាត់ត្រូវធ្វើការវះកាត់[22]។ ទោះបីការវះកាត់ អៀង ធីរិទ្ធ ទទួលបានជោគជ័យក៏ដោយ តែគាត់ត្រូវសម្រាកនៅពេទ្យនោះដើម្បីព្យាបាលបញ្ហាបេះដូង និង សួត[23]។ បន្ទាប់ពីចេញពីមន្ទីរពេទ្យ និង វិលត្រឡប់ទៅផ្ទះគាត់នៅខេត្តប៉ៃលិន ប្រទេសកម្ពុជាវិញ អាណាព្យាបាលរូបនេះបានរាយការណ៍មកអង្គជំនុំជម្រះថា អៀង ធីរិទ្ធ ត្រូវបន្តទៅពិនិត្យយ៉ាងយកចិត្តទុកដាក់ និង មានការណាត់ជួបជាមួយគ្រូពេទ្យនៅមន្ទីរពេទ្យ Bangkok Hospital[24]។ នៅថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៤ អាណាព្យាបាលរូបនេះបានរាយការណ៍ថា អៀង ធីរិទ្ធ ត្រូវសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរយៈពេលពីរខែកន្លះ[25]។ ចាប់តាំងពីពេលនោះមក អៀង ធីរិទ្ធ វិលត្រឡប់ទៅមន្ទីរពេទ្យ Bangkok Hospital ជារឿយៗ ដើម្បីបន្តព្យាបាលជំងឺខ្វះគ្រាប់ឈាមក្រហម

---

19 របាយការណ៍អំពីលទ្ធផលថតស្កេនថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ១១។

20 លិខិតរបស់ អៀង វិជីរ៉ា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ស្នើសុំនាំអ្នកស្រី អៀង ធីរិទ្ធ ទៅព្យាបាលនៅប្រទេសថៃ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ E138/1/11 ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៤។

21 សំណើសុំបញ្ជូន អៀង ធីរិទ្ធ ទៅកាន់ប្រទេសថៃដើម្បីព្យាបាលជំងឺ ឯកសារ E138/1/11/2 ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៥។

22 លិខិតរបស់ អៀង វិជីរ៉ា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ E138/1/11/2/3 ("លិខិតចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤") ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤។

23 លិខិតចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤។

24 របាយការណ៍អំពីស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ E138/1/11/2/2 ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៤។

25 លិខិតរបស់ អៀង វិជីរ៉ា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ E138/1/11/4 ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៤។

ការចុះខ្សោយមុខងារបេះដូង និង តម្រងនោម[26]។ ក្នុងអំឡុងពេលសម្រាកព្យាបាលជាញឹកញយនៅប្រទេសថៃ អង្គជំនុំជម្រះសាលាដំបូងមិនបានបង្គាប់ឱ្យធ្វើការត្រួតពិនិត្យរៀងរាល់ប្រាំមួយខែទេ។

៧. នៅថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាមួយឱ្យបន្តការត្រួតពិនិត្យជាទៀងទាត់រៀងរាល់ប្រាំមួយខែឡើងវិញ និង បានចាត់តាំងអ្នកជំនាញម្នាក់ ដែលជាគ្រូពេទ្យព្យាបាលមនុស្សចាស់ឱ្យធ្វើការពិនិត្យ អៀង ធីរិទ្ធ[27]។ នៅពេលនោះ អៀង ធីរិទ្ធ ធ្លាក់ខ្លួនឈឺធ្ងន់មិនអាចធ្វើដំណើរមកភ្នំពេញដើម្បីធ្វើការពិនិត្យបានទេ[28]។ នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៥

---

[26] លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ E138/1/11/3/2 ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ E138/1/11/5 ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១៤, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ E138/1/11/6 ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ E138/1/11/8 ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ E138/1/11/9 ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ E138/1/11/10 ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៤, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E138/1/11/11 ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E138/1/11/12 ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៥, លិខិតរបស់ អៀង វិជីដា ផ្ញើជូនប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងស្ថានភាពជំងឺរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ E138/1/11/13 ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៥។

[27] ដីកាចាត់តាំងអ្នកជំនាញដើម្បីពិនិត្យ និង វាយតម្លៃសម្បទា អៀង ធីរិទ្ធ ឯកសារ E138/1/10/1/5/9/7 ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៣។

[28] លិខិតរបស់ប្រធានមន្ទីរពេទ្យខេត្តប៉ៃលិន ចុះថ្ងៃទី ២២ មិថុនា ឆ្នាំ ២០១៥ ឯកសារ E138/1/11/13.1 ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៥។

អ្នកជំនាញបានធ្វើការពិនិត្យ អៀង ធីរិទ្ធ នៅលំនៅដ្ឋានរបស់គាត់នៅក្រុងប៉ៃលិន ប្រទេសកម្ពុជា[29] ។ អ្នកជំនាញបានសង្កេតឃើញថា សាច់ដុំជើងរបស់ អៀង ធីរិទ្ធ ថយចុះ រួមជាមួយនឹងសញ្ញាផ្សេងៗទៀតបង្ហាញថា គាត់ត្រូវនៅសម្រាកលើគ្រែ[30]។ អ្នកជំនាញព្យាយាមសន្ទនាជាមួយ អៀង ធីរិទ្ធ និង បានសាកសួរពីអារម្មណ៍របស់គាត់[31]។ អៀង ធីរិទ្ធ មិនបានឆ្លើយតបទេ ទោះបីគាត់បើកភ្នែក ហើយបន្ទាប់មកបិទទៅវិញយ៉ាងរហ័សច្រើនដងក៏ដោយ[32]។ អ្នកជំនាញមិនអាចធ្វើការវាយតម្លៃសតិបញ្ញាជាលក្ខណៈស្តង់ដាដែលអ្នកជំនាញមានបំណងប្រើទេ[33]។ ហេតុនេះ អៀង ធីរិទ្ធ ទទួលបានពិន្ទុ 0 លើ ៣0[34]។ ការប្រើមាត្រដ្ឋាននៃការធ្លាក់ចុះជាសាកល អៀង ធីរិទ្ធ ទទួលបានពិន្ទុ ៧ មានន័យថា គាត់ស្ថិតនៅក្នុងដំណាក់កាលធ្ងន់ធ្ងរបំផុតនៃជំងឺវង្វេងវង្វាន់ស្មារតី[35]។ អ្នកជំនាញបានសន្និដ្ឋានថា អៀង ធីរិទ្ធ មានជំងឺវង្វេងវង្វាន់ស្មារតីកម្រិតធ្ងន់ធ្ងរ ដោយមានភាពប្រាកដប្រជាផ្នែកវេជ្ជសាស្ត្រ[36]។

៨. អ្នកជំនាញក៏បានរាយការណ៍ផងដែរថា គ្មានការព្យាបាលផ្នែកវេជ្ជសាស្ត្រណាមួយដែលអាចធ្វើឱ្យស្ថានភាពសតិបញ្ញារបស់ អៀង ធីរិទ្ធ មានភាពប្រសើរឡើងវិញទេ[37]។ អៀង ធីរិទ្ធ មិនអាចក្រោកចេញពីគ្រែបាន និង មានជំងឺក្នុងខ្លួនជាច្រើន[38]។ អ្នកជំនាញគ្មានការសង្ស័យទេថា ស្ថានភាពរាងកាយរបស់គាត់ គឺជាការពិត ហើយបានសន្និដ្ឋានថា អៀង ធីរិទ្ធ កំពុងទទួលការថែទាំមុនពេលគាត់ស្លាប់[39]។

---

29 របាយការណ៍វេជ្ជសាស្ត្ររបស់អ្នកជំនាញ - អៀង ធីរិទ្ធ ឯកសារ E138/1/10/1/5/9/8 (“របាយការណ៍របស់អ្នកជំនាញ”) ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ៨។

30 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ១៨, ១៩។

31 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២២។

32 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២២។

33 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២២។

34 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២២។

35 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២៥។

36 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២៥។

37 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២៦។

38 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២៧។

39 របាយការណ៍របស់អ្នកជំនាញ កថាខណ្ឌ ២៧។

៩. បើតាមលិខិតមរណភាព និង កំណត់ហេតុស្តីពីមរណភាពរបស់ អៀង ធីរិទ្ធ ដែលបានចេញដោយ ចៅសង្កាត់ក្រុងប៉ៃលិន និង អនុប្រធានមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន បង្ហាញថា អៀង ធីរិទ្ធ បាន ទទួលមរណភាពនៅខេត្តប៉ៃលិន ប្រទេសកម្ពុជា នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥[40]។ គាត់បាន ទទួលមរណភាពនៅឯគេហដ្ឋានរបស់គាត់ដោយសារតាំងបេះដូង[41]។

## ២. ច្បាប់ជាធរមាន

១០. អនុលោមតាមមាត្រា ៧(១) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មរណភាពរបស់ជនជាប់ចោទត្រូវ រលត់បណ្តឹងអាជ្ញាប្រឆាំងនឹងរូបគាត់[42]។ អនុលោមតាមវិធាន ២៣*ស្ទួន* នៃវិធានផ្ទៃក្នុង មរណ-ភាពរបស់ជនជាប់ចោទក៏បញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងរដ្ឋប្បវេណីផងដែរ នៅ អ.វ.ត.ក[43]។

**ដោយសារមានសំអាងហេតុនានាខាងលើ អង្គជំនុំជម្រះសាលាដំបូង**

**សម្រេច** ថាមរណភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ មានអានុភាពរលត់បណ្តឹងអាជ្ញា និង បញ្ចប់ បណ្តឹងរដ្ឋប្បវេណីប្រឆាំងរូបគាត់នៅ អ.វ.ត.ក។

ភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C * C.E.T.C

និល ណុន

[40] សំបុត្រមរណភាពរបស់ អៀង ធីរិទ្ធ ឯកសារ E359.3 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥, កំណត់ហេតុស្តីអំពីមរណភាព របស់លោកស្រី អៀង ធីរិទ្ធ ឯកសារ E359.1 (“កំណត់ហេតុ”) ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥។

[41] លិខិតមរណភាពរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ E359 ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥, កំណត់ហេតុ។

[42] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៧(១)។

[43] វិធាន ២៣*ស្ទួន*(៦) នៃវិធានផ្ទៃក្នុង, សូមមើលផងដែរ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងជនជាប់ចោទ អៀង សារី ឯកសារ E270/1 ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣ ជើងទំព័រ ៨។